# *សិលាចារឹកបន្ទាយនាង (K.1292)*

*យោងតាមអត្ថបទរបស់លោក លឹម វណ្ណច័ន្ទ រៀបរាប់ថា ភ្នំបន្ទាយនាង ជាភ្នំថ្មកំបោរដែលមានអាយុកាលស្ថិតនៅក្នុងស័កទី១ Paleozoic សម័យ Permian (២៥១-២៩៩លានឆ្នាំ)។ លុះមកដល់សម័យមុនអង្គរ (ស.វ.ទី៧) រូងភ្នំបន្ទាយនាង បានក្លាយទៅជាទេវស្ថានមួយកន្លែង ដែលមានសេសសល់នូវបំណែកឥដ្ឋបុរាណ ចម្លាក់នៅក្នុងរូងភ្នំ និងជាពិសេស គឺមានអក្សរចារឹកជាភាសាសំស្រ្កឹតនៅជាប់ជញ្ជាំងរូងភ្នំចំនួន ២ ផ្ទាំងផងដែរ (ស្ថិតនៅក្បែរគ្នា)។ តើសិលាចារឹកនៅភ្នំបន្ទាយនាង មានខ្លឹមសារ និងអត្ថន័យយ៉ាងដូចម្តេចខ្លះ?*

*អត្ថបទសិលាចារឹកនេះ សរសេរជាភាសាសំស្រ្កឹត មានចំនួន ២ ទីតាំង ដែលយោងទៅតាមអក្សរចារឹក គឺអាចមានអាយុកាលនៅស.វ.ទី៧។ សិលាចារឹកផ្ទាំងទី១ មានត្រឹមតែមួយបន្ទាត់ប៉ុណ្ណោះ ដែលរៀបរាប់ថា "បាណិបាត្រ"។ បើប្រែតាមពាក្យនីមួយៗ ពាក្យថា "បាណិ" អាចប្រែថា "ដៃ" រីឯពាក្យថា "បាត្រ" សំដៅដល់ភាជន៍មួយប្រភេទសម្រាប់ដាក់អ្វី ដូចជា បាត្រព្រះសង្ឃ ប៉ុន្តែក៏អាចសំដៅដល់ថូទឹក ឬក្អមដាក់ទឹកផងដែរ។ ដូច្នេះ ពាក្យ "បាណិបាត្រ" អាចសំដៅដល់ "**អ្នកបួសមានបាតដៃជាភាជន៍**"។ រីឯមួយផ្ទាំងទៀត មានចំនួន ៤ បន្ទាត់ ចារឹកជាភាសាសំស្រ្កឹតដូចគ្នា។ ស្លោកទី១ ចារឹកតាមបែបត្រិស្តុភឆន្ទ និងស្លោកទី២ ចារឹកតាមបែប គក្វរីវសន្តតិលកាឆន្ទ។ ខ្លឹមសារជារួមនៃអក្សរចារឹកផ្ទាំងទី២នេះ ស្លោកទី១ពណ៌នាអំពីរឿងនិទានអំពីព្រះទេវាតិទេវ (ព្រះឥសូរ) ដែលមានតាំងតែពីបុរាណកាលនៅលើបព៌ត (ភ្នំ) នេះ ដោយបានកសាងគុហានេះសម្រាប់គោរពបូជាដោយក្រុម "បាណិបាត្រៈ" (អ្នកបួសមានបាតដៃជាភាជន៍)។ រីឯស្លោកទី២ ពណ៌នាអំពីការគោរពប្រណិប័តន៍បម្រើព្រះលិង្គៈ និងព្រះវ្ឫកៈ (គោនន្ទិ) ដោយក្រុម បាណិបាត្រៈ។*

## អត្ថបទចារឹក និងសេចក្តីប្រែ

### ឧបជាតិឆន្ទ

១. អក្ឫតបូវ៌្វកិលបវ៌្វតេស្មិ ន្ទេវាតិទេវាច.....
ចការកត្ត្យាសចចាណិចាត្រោ គុហាមិមាំសមមុ..។

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

*ប្រែថា៖* *រឿងរ៉ាវនៃព្រះទេវាតិទេវ..... បានកើតឡើងតាំងពីបុរាណកាលនៅក្នុងបព៌ត (ភ្នំ) នេះ ហើយតាបសបាណិបាត្រៈ (អ្នកបួសមានបាតដៃជាភាជន៍) បានកសាងនូវគុហានេះដោយកក្តីភាពយ៉ាង......។*

**វសន្តតិលកាឆន្ទ**

២. យស្មិន្តចោរលវិធ្វតរជោវិការេ សព្យាបសព្យតិវិកាណិ..យោន្ទុជាតៅ
យេជាបិ លិង្គវ្រូមកៅ និលយានិបុម្បៃះ កុត្រូមិតៅប្រតិនិធំសតុចាណិចាត្រះ។

*ប្រែថា៖* *មន្ត្រីម្នាក់ណាជាអាមាត្យត្រួតអធិការកិច្ចជាអ្នកជំនាញនូវកិច្ចការ និងជាលេខាធិការ (ដែលត្រូវបានតែងតាំងហើយ) ដោយព្រះរាជាព្រះបាទគ្រីឦគានវម៌្មទី១ ជាស្តេចដែលមានមហាអំណាចដ៏ឆាប់រហ័ស។*

៣. តេយ៉ំត្យាគានិយុក្តេន រាជ្ញា ត្រីភវវម៌្មណា
យត្វាជ៌វស្តុគណាជា- និយុក្តោ លេខវាចកះ។

*ប្រែថា៖* *មន្ត្រីម្នាក់ណាក៏ជាមន្ត្រីបម្រើខាងគណនានៃភស្តុភារពាក់កណ្តាល និងជាលេខាធិការ (ដែលត្រូវបានតែងតាំងហើយ) ដោយព្រះរាជាព្រះបាទគ្រីភវវម៌្មទី២ ដែលជាស្តេចប្រកបដោយភាពក្លាហាន និងការបរិច្ចាគទានជាអាទិ៍។*

៤. អា ចម្បាន្តមិជយិនា រាជ្ញាត្រីជយវម៌្មណា
សន្នាទ្យសិទ្ធាយតន- ចាលនេ......មត្បិតះ។

*ប្រែថា៖* *នៅក្នុងគុហានោះ នៅពេលដែលវិការនៃធូលីត្រូវបានលុបបំបាត់ដោយអំណាចតបៈ តាបសបាណិបាត្រៈនោះ ក៏បានបម្រើព្រះលិង្គៈ និងព្រះវ្រូមកៈ (គោនន្ទិ) ដោយផ្កាផ្សេងៗ និងគ្រឿងបូជាដទៃទៀតជារៀងរាល់ថ្ងៃ។*

*(សម្គាល់៖ ពាក្យ បាណិបាត្រៈ សំដៅលើអ្នកបួស ឬអ្នកតាំងសមាធិទាំងឡាយណាដែលប្រើបាតដៃរបស់ខ្លួនជាភាជន៍សម្រាប់ទទួលអាហារ)។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

សរុបជារួមមក សិលាចារឹកភ្នំបន្ទាយនាង (K.1292) បានផ្តល់ព័ត៌មានមួយចំនួនអំពីការប្រណិប័តន៍ជំនឿតាមបែបព្រហ្មញ្ញសាសនា និកាយសៃវ របស់អ្នកបួសនៅសម័យមុនអង្គរ ហើយស្តែងឱ្យឃើញអំពីការមានជំនឿទៅលើរូងភ្នំជាកន្លែងស័ក្តសិទ្ធិ។

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់



រូបលេខ១៖ ទីតាំងអក្សរចារឹកនៅរូងភ្នំបន្ទាយនាង (ថតឆ្នាំ ២០១៧)

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់



រូបលេខ២២៖ សកម្មភាពផ្ដិតអក្សរចារឹកនៅរូងភ្នំបន្ទាយនាង (ថតឆ្នាំ ២០១៧)



រូបលេខ២៣៖ សំណៅផ្ដិតអក្សរចារឹកនៅរូងភ្នំបន្ទាយនាង (២៤ សីហា ២០១៧)
(ផ្ដិតដោយ៖ កំ វណ្ណារ៉ា)

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់